# កិច្ចព្រមព្រៀងពាណិជ្ជកម្ម
# រវាង
# រាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាល នៃ សាធារណរដ្ឋប្រជាមានិតបង់ក្លាដែស

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ដែលបន្ទាប់ទៅនេះហៅកាត់ថា " **ភាគីចុះហត្ថលេខា** " ។

ក្នុងគោលបំណង ពង្រឹង និង ពង្រីកទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ផ្អែកលើមូលដ្ឋាននៃគោលការណ៍សមភាពមានផលប្រយោជន៍ទៅវិញទៅមក និងអត្ថប្រយោជន៍ ដែលបានការអនុគ្រោះបំផុត ដើម្បីលើកកំពស់ កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច របស់ភាគីទាំងសងខាង។

ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោមៈ

## មាត្រា ១

ផ្អែកតាមក្រមខណ្ឌច្បាប់និងបទបញ្ញត្តិដែលមាន ភាគីចុះហត្ថលេខាទាំងពីរ ត្រូវប្រកាន់យកវិធានការណ៍សមស្របដើម្បីសំរួល ពង្រឹងនិងធ្វើឱយកាន់តែប្រសើរសំបូរបែបឡើងនូវចំណងទាក់ទងពាណិជ្ជកម្ម រវាងប្រទេសទាំងពីរលើមូលដ្ឋានយូរអង្វែងនិងមានស្ថិរភាព។

## មាត្រា ២

តាមប្រការនានានៃច្បាប់និងបទបញ្ញត្តិជាធរមានក្នុងប្រទេសរបស់ខ្លួន ភាគីចុះហត្ថលេខាទាំងពីរ ត្រូវផ្តល់ឱយគ្នាទៅវិញទៅមកនូវឋានៈជាប្រជាជាតិអនុគ្រោះបំផុត ចំពោះកាតព្វកិច្ចខាងពន្ធគយនឹងពន្ធអាករផ្សេងៗទៀត ដែលអនុវត្តក្នុងការផ្លាស់ប្តូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ដូចដែលបានព្រមព្រៀងដោយប្រទេសទាំងពីរ ស្ថិតក្នុងក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។

## មាត្រា ៣

ប្រការដែលមានចែងក្នុងមាត្រា ២ មិនត្រូវបានចាត់ទុកជាការទប់ស្កាត់ចំពោះ :

១- ភាគីណាមួយក្នុងចំណោមភាគីចុះហត្ថលេខាទាំងពីរ បានទទួលឬសំរបសំរួលផលប្រយោជន៍របស់ខ្លួនចំពោះប្រទេសជិតខាងដើម្បីសំរួលការផ្លាស់ប្តូរទំនិញពាណិជ្ជកម្មដោយកំណត់ត្រឹមលក្ខណៈនៃតំបន់ពាណិជ្ជកម្មតាមព្រំដែនដែលការធ្វើពាណិជ្ជកម្មនេះបានកើតឡើង នឹង

២- ភាគីណាមួយក្នុងចំណោមភាគីចុះហត្ថលេខាទាំងពីរ លើកលែងនូវលក្ខណៈអនុគ្រោះនានាដែលជាលទ្ធផលបានមកពីការធ្វើពាណិជ្ជកម្មតាមរបៀបអនុគ្រោះណាមួយ ឬតាមការរៀបចំក្រុមសេដ្ឋកិច្ចក្នុងតំបន់ដែលភាគីណាមួយនៃភាគីចុះហត្ថលេខាទាំងពីរជាសមាជិក ។

ពាណិជ្ជកម្មទំនិញរវាងប្រទេសទាំងពីរនឹងត្រូវអនុវត្តផ្អែកតាមច្បាប់និងបទបញ្ញត្តិជាធរមានរបស់ប្រទេសទាំងពីរ ។

## មាត្រា ៤

ភាគីចុះហត្ថលេខាទាំងពីរ ត្រូវព្រមព្រៀងគ្នា ដោយផ្អែកតាមច្បាប់ និងបទបញ្ញត្តិជាធរមានដើម្បី :

ក- សំរួល ការចូលរួមក្នុងផ្សារណាត់ និងពិពណ៌ពាណិជ្ជកម្ម

ខ- រៀបចំទស្សនកិច្ចរបស់ពាណិជ្ជករនៃមជ្ឈមណ្ឌលពាណិជ្ជកម្មនានា

គ- លើកលែងពន្ធគយនិងអាករនិងចំណាយដូចគ្នាផ្សេងទៀត លើទំនិញនិងទំនិញគំរូក្នុងគោលបំណងប្រើប្រាស់តែក្នុងរយៈពេលធ្វើពិពណ៌ពាណិជ្ជកម្ម និងផ្សារណាត់ សំរបសំរួលការចូលការនាំចេញបន្ត ការលក់និងបែងចែកទំនិញនៅកន្លែងផ្សារណាត់និងការតាំងពិពណ៌ ។

## មាត្រា ៥

រាល់ការទូទាត់ក្រោមកិច្ចព្រមព្រៀងនេះរវាងប្រទេសទាំងពីរនឹងត្រូវធ្វើឡើងដោយសេរីលើគ្រប់រូបិយប័ណ្ណដែលអាចផ្ទេរប្តូរបានដោយអនុលោមតាមច្បាប់និងបទបញ្ញត្តិដែលមានជាធរមាននៃប្រទេសទាំងពីរ ។

## មាត្រា ៦

ស្របតាមច្បាប់និងបញ្ញាត្តិដែលមាន ភាគីចុះហត្ថលេខានីមួយៗ ត្រូវយល់ព្រមផ្តល់ដល់បុគ្គលនៃភាគីម្ខាងទៀតដោយផ្អែក តាមមាត្រានានានៃកិច្ចព្រមព្រៀងនេះនូវជំនួយជាចាំបាច់ ដើម្បីសំរួលដល់ការបំពេញ ការងារ និងធានាឱ្យការអនុវត្តការងាររបស់គេទទួលបានជោគជ័យ ។

## មាត្រា ៧

អ្នកតំណាងនៃភាគីចុះហត្ថលេខាទាំងពីរ នៅពេលមានសំណូមពរពីភាគីណាមួយត្រូវពិភាក្សាលើកឡើងនូវវិធានការណ៍ចាំបាច់សំដៅពង្រឹង និងពង្រីកទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរនិងលើកឡើងនូវដំណោះស្រាយលើរាល់បញ្ហាដែលកើតឡើង ពីការអនុវត្តន៏កិច្ចព្រមព្រៀងនេះដោយឈរលើស្មារតីសហប្រតិបត្តិការនិងការយោគយល់គ្នាទៅវិញទៅមក ។ ទីកន្លែងនិងកាលបរិច្ឆេទនៃការពិភាក្សារបៀបនេះនឹងត្រូវកំណត់ឡើង ប្រសិនបើចាំបាច់ដោយការយល់ព្រមទៅវិញទៅមក ។

## មាត្រា ៨

កិច្ចព្រមព្រៀងនាពេលបច្ចុប្បន្ននេះនឹងមិនរារាំងដល់ភាគីណាមួយនៃភាគីចុះហត្ថលេខាទាំងពីរ ចំពោះការអនុវត្ត ការហាមឃាត់ ឬការដាក់កំហិតដោយវិធានការណ៍ណាមួយដែលសំដៅការពារដោយផ្ទាល់នូវប្រយោជន៍សុវត្ថិភាពជាសារវន្ត សីលធម៌សាធារណៈ សុខភាពសាធារណៈ ការការពារជំងឺផ្សេងៗ និងការការពាររោគឆ្លងដល់សត្វពាហនៈនិងរុក្ខជាតិទេ ។រាល់ការហាមឃាត់ឬការដាក់កំហិតនានាលើការធ្វើពាណិជ្ជកម្មត្រូវជូនដំណឹងគ្នាជាមុនជាលាយលក្ខ័អក្សរ ។

## មាត្រា ៩

ក្នុងករណីមានវិវាទកើតមានឡើងពីការបកស្រាយ ឬ ការអនុវត្តមាត្រានានា នៃកិច្ចព្រមព្រៀងនេះត្រូវដោះស្រាយដោយមិត្តភាពតាមផ្លូវការទូតរវាងភាគីហត្ថលេខីទាំងពីរ។ ប្រសិនបើវិវាទរវាងភាគីទាំងពីរជាបញ្ហាដែលកើតមានឡើងស្របតាមកិច្ចព្រមព្រៀង ហើយមិនអាចដោះស្រាយជាមិត្តភាពតាមផ្លូវការទូតក្នុងរយៈពេល៣០ថ្ងៃក្រោយភាគីណាមួយបានទទួលសំណើពីភាគីម្ខាងទៀត ទំនាស់នោះអាចនឹងត្រូវបានបញ្ជូនទៅ

ទៅភាគីម្ខាងទៀតដើម្បីធ្វើការដោះស្រាយតាមរយៈអាជ្ញាកណ្តាល ដោយអនុលោមតាមច្បាប់ស្តីពីអាជ្ញាកណ្តាល UNCITRAL ដែលមានជាធរមានក្នុងពេលបច្ចុប្បន្ន ។

## មាត្រា ១០

កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា។ កិច្ចព្រមព្រៀងនេះត្រូវមានសុពលភាពរយៈពេល ០៥ (ប្រាំ) ឆ្នាំ ហើយនឹងត្រូវបន្តពន្យារពេលដោយស្វ័យប្រវត្តិសំរាប់រយៈពេល ០៥ (ប៉ាំ) ឆ្នាំទៀត លើកលែងតែមានភាគីណាមួយជូនដំណឹង ជាលាយល័ក្ខអក្សរអំពីគោលបំណងរបស់ខ្លួន ក្នុងការបញ្ចប់កិច្ចព្រមព្រៀងនេះរយះពេល ០៣ (បី) ខែ មុនពេលកិច្ចព្រមព្រៀងនេះអស់សុពលភាព ។

ដោយអនុលោមតាមកិច្ចសន្យាដែលបានចុះហត្ថលេខាក្នុងរយៈពេលសុពលភាពនៃកិច្ចព្រមព្រៀងទាំងឡាយនៃកិច្ចព្រមព្រៀងដែលមិនទាន់បានអនុវត្តចប់សព្វគ្រប់ នឹងនៅអាចអនុវត្តបានក្រោយពេលដែលកិច្ចព្រមព្រៀងនេះត្រូវបានបញ្ចប់ ។

ដោយយោលតាមសំណូមពររបស់ភាគីណាមួយ កិច្ចព្រមព្រៀងបច្ចុប្បន្នអាចបំពេញបន្ថែមឬកែប្រែដោយការយល់ព្រមពីភាគីទាំងសងខាង។

ជាសក្ខីភាពអ្នកចុះហត្ថលេខាខាងក្រោម ដោយបានទទួលសិទ្ធិប្រទានពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០០៦ ជា ០៣ (បី) ច្បាប់ដើម ជាភាសាខ្មែរ. បង់ក្លា និងអង់គ្លេស ។ អត្ថបទទាំងអស់មានតំលៃតាមផ្លូវច្បាប់ស្មើគ្នា ។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវបានយកជាគោល ។

**ជ.រាជរដ្ឋាភិបាល នៃ**
**ព្រះរាជាណាចក្រកម្ពុជា**

**ជ.រដ្ឋាភិបាល នៃ**
**សាធារណរដ្ឋប្រជាមានិតបង់ក្លាដែស**